ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

សេចក្តីជូនដំណឹង
ស្តីពី
ការទប់ស្កាត់ការផ្សព្វផ្សាយ និងការជ្រើសរើសមនុស្សទៅធ្វើការនៅទ្វីបអាហ្វ្រិក

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា បច្ចុប្បន្ន ក្រសួងបានសង្កេតឃើញថា មានប្រជាពលរដ្ឋខ្មែរមួយចំនួនបានចេញទៅធ្វើការនៅទ្វីបអាហ្វ្រិក។ ក្រសួងសូមជម្រាបជូនថា រាជរដ្ឋាភិបាលកម្ពុជាពុំទាន់មានកិច្ចព្រមព្រៀងស្តីពីការផ្លាស់ប្តូរកម្លាំងពលកម្ម និងការបញ្ជូនបុគ្គលិក ឬពលករកម្ពុជាទៅធ្វើការនៅបណ្តាប្រទេសនៃទ្វីបអាហ្វ្រិកនៅឡើយទេ។ ការចេញទៅធ្វើការនៅប្រទេសដែលកម្ពុជាពុំទាន់មានកិច្ចព្រមព្រៀងជាមួយ អាចប្រឈមនឹងហានិភ័យខ្ពស់ ជាពិសេសងាយធ្លាក់ខ្លួនជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស។

ក្នុងស្មារតីនេះ ក្រសួងសូមក្រើនរំឭក និងអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋខ្មែរទាំងអស់មេត្តាប្រុងប្រយ័ត្នឱ្យបានខ្ពស់បំផុតចំពោះការផ្សព្វផ្សាយ ឬការដើរអូសទាញពីបុគ្គល ឬក្រុមហ៊ុនណាមួយថាកំពុងមានការជ្រើសរើសបុគ្គលិក ឬពលករកម្ពុជាទៅធ្វើការនៅទ្វីបអាហ្វ្រិក ដោយសន្យាបញ្ជូនមនុស្សទៅធ្វើការដោយផ្ទាល់ ឬតាមមធ្យោបាយប្រទេសទី៣បន្តទៅដល់ទ្វីបអាហ្វ្រិក ព្រមទាំងធានាការផ្តល់ប្រាក់ឈ្នួលខ្ពស់ ឬផ្តល់ប្រាក់ឧបត្ថម្ភដល់គ្រួសារជាមុនឱ្យសោះ។

ចំពោះមុខនេះ ការផ្សព្វផ្សាយ ឬការចុះជ្រើសរើសមនុស្សចេញទៅធ្វើការនៅទ្វីបអាហ្វ្រិកគឺជាទង្វើខុសច្បាប់។ ក្នុងករណីសាធារណជនបានដឹង បានឮ ឬបានឃើញសកម្មភាពទាំងនេះ សូមមេត្តាប្រញាប់ជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ចដែលនៅកៀកបំផុតដើម្បីចុះឃាត់ខ្លួន និងទប់ស្កាត់ជាបន្ទាន់។ ក្នុងករណីមានការសង្ស័យ ឬត្រូវការព័ត៌មានបន្ថែម សូមទាក់ទងតាមរយៈប្រព័ន្ធ Hotline លេខ ១២៩៧។

អាស្រ័យហេតុនេះ សូមសាធារណជន មេត្តាជ្រាបជាព័ត៌មាន ចូលរួមសហការផ្សព្វផ្សាយ និងទប់ស្កាត់ឱ្យបានទាន់ពេលវេលា។

ថ្ងៃព្រហស្បតិ៍ ២រោច ខែកត្តិក ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៦